762	សាងសង់ផ្លូវជាតិលេខ ៧៦ បេ	6.150	2.460	1.669		4.129
755	កម្មវិធីបណ្ដុះបណ្ដាលសាងសង់ និងគ្រប់គ្រងអាកាសយានដ្ឋាន	1.640	820			820
863	ស្ពានផ្លូវជាតិ (អន្លង់វែង-ព្រះវិហារ)	100.450	3.280	2.050	2.050	7.380
1008	សាងសង់ឡើងវិញផ្លូវជាតិលេខ ៧៤	28.700	2.050	2.050	2.460	6.560
1010	សាងសង់ផ្លូវអាស៊ាន ផ្លូវជាតិលេខ ៦៦ (២៧៥គម)	287.000	2.050	2.050	2.870	6.970

ប្រភព: ក្បាលចំណងជើងពីក្រសួង-ស្ថាប័ននានា។ ប្រភពព័ត៌មាន: ទិន្នន័យនៃកម្មវិធីវិនិយោគសាធារណៈ ក្រសួងផែនការ

ការគ្រប់គ្រងឆ្នាំ ២០១០

តារាង "គ២"

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា:លានរៀល

លេខគម្រោង	ឈ្មោះគម្រោង	តំលៃគម្រោង	កម្រិតទុនវិនិយោគចែកតាមឆ្នាំ			
			២០១០	២០១១	២០១២	សរុប ៣ ឆ្នាំ
1309	គម្រោងអភិវឌ្ឍន៍កំពង់ផែទៅតាមបណ្តោយដងទន្លេមេគង្គ បាសាក់ និង ទន្លេសាប	36.490	2.460	2.665	820	5.945
1361	បង្កើនសមត្ថភាពសម្ភារៈសាងសង់ផ្លូវ	20.500	4.100			4.100
1362	កម្មវិធីស្តារស្ពានបន្ទាន់	41.000	3.280	3.485		6.765
រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល		202.581	11.337	11.111	10.250	32.698
3	គម្រោងអភិវឌ្ឍន៍អាកាសយានដ្ឋានព្រះវិហារ	34.850	2.870	2.050	2.050	6.970
420	គម្រោងអភិវឌ្ឍន៍អាកាសយានដ្ឋានមណ្ឌលគិរី	94.300	2.050	2.050	3.280	7.380
423	គម្រោងអភិវឌ្ឍន៍អាកាសយានដ្ឋានរតនគិរី	22.960	2.050	2.050	2.050	6.150
424	គម្រោងអភិវឌ្ឍន៍អាកាសយានដ្ឋានស្ទឹងត្រែង	23.821	2.317	2.911	820	6.048
1325	គម្រោងអភិវឌ្ឍន៍អាកាសយានដ្ឋានក្រចេះ	26.650	2.050	2.050	2.050	6.150
ក្រសួងព័ត៌មាន		97.191	13.838	14.252	19.680	47.769
99	អភិវឌ្ឍន៍គម្រោងវិទ្យុជាតិ AM/FM ខេត្ត-រាជធានី	46.945	7.688	7.692	12.300	27.679
334	សាងសង់ស្ថានីយទូរទស្សន៍ ខេត្ត-រាជធានី	26.650	2.050	2.050	2.050	6.150
416	ការបង្កើតទំនាក់ទំនងរួមផ្នែកព័ត៌មានប្រទេសអាស៊ាន	18.450	2.050	2.460	3.280	7.790
1421	បង្កើនសមត្ថភាពសារព័ត៌មាន AKP	5.146	2.050	2.050	2.050	6.150
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍		634.270	56.535	31.070	49.044	136.649
294	បណ្តាញទូរគមនាគមន៍ក្របខ័ណ្ឌមហាតំបន់ទន្លេមេគង្គ	123.000	45.875			45.875
295	បណ្តាញទូរគមនាគមន៍ព័ត៌មានវិទ្យាមហាអនុតំបន់ទន្លេមេគង្គ	75.850				
401	បណ្តាញបញ្ជូនស៊ីញ៉ាល់ ភ្នំពេញ-ខេត្តព្រះសីហនុ	41.000	820	820	4.100	5.740
1328	ប្រអប់ទូរស័ព្ទសាធារណៈ	34.850	1.640	1.640	3.485	6.765
1326	ពង្រីកបណ្តាញបញ្ជូនស៊ីញ៉ាល់ដោយប្រើកាប្លិអុបទិក	155.800	1.230	10.980	16.859	29.069
1468	ហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍន៍ទូរគមនាគមន៍អនុតំបន់ទន្លេមេគង្គ	191.470	4.100	14.350	20.500	38.950
1469	គ្រប់គ្រងព័ត៌មានវិទ្យា	12.300	2.870	3.280	4.100	10.250
ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ		120.224	12.825	40.483	59.274	112.582
213	មជ្ឈមណ្ឌលវប្បធម៌	45.100	2.050	14.350	26.650	43.050
217	ជួសជុលប្រាសាទបុរាណ (ក្រៅតំបន់អង្គរ)	28.905	2.050	9.098	12.300	23.448
739	ជួសជុលសំណង់ចាស់ៗ និងផ្លូវទៅភ្នំព្រះរាជទ្រព្យ	28.700	2.583	10.853	15.264	28.700
[illegible]	[illegible]រៀបចំមជ្ឈមណ្ឌលវប្បធម៌ជនជាតិនៅភូមិភាគឦសាន	3.280	1.107	1.087	1.087	3.280
	សាងសង់អគារមន្ទីរតាមបណ្តាខេត្ត-រាជធានី នៅជុំវិញបឹងទន្លេសាប	6.150	2.468	2.456	1.226	6.150
[illegible]	ជួសជុលបណ្ណាល័យជាតិ ជំហាន ២	6.150	2.050	2.050	2.050	6.150

ប្រភព: ករណីជាឯកសារទិន្នន័យពីក្រសួង-ស្ថាប័ននានា ។ ប្រភពព័ត៌មាន: ទិន្នន័យនៃកម្មវិធីវិនិយោគសាធារណៈ ក្រសួងផែនការ

4/54

ការគ្រប់គ្រងឆ្នាំ ២០១០

តារាង "គ២"

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា:លានរៀល

លេខ / គម្រោង	ឈ្មោះគម្រោង	តំលៃគម្រោង	កម្រិតមូលនិធិវិនិយោគចែកតាមឆ្នាំ			
			២០១០	២០១១	២០១២	សរុប ៣ ឆ្នាំ
1478	អភិរក្ស និងជួសជុលប្រាសាទតាព្រហ្ម (បន្ទាយឆ្មារ)	914	258	295	349	902
1479	សង់ការិយាល័យអភិរក្សដ្ឋានប្រចាំខេត្តបន្ទាយមានជ័យ និងបាត់ដំបង	1.025	258	295	349	902
	ក្រសួងធម្មការ និងសាសនា	16.847	3.583	5.613	7.651	16.847
509	ជួសជុលកែលម្អបណ្ណាល័យក្រសួង	5.535	1.845	1.845	1.845	5.535
558	ជួសជុលកែលម្អកន្លែងធ្វើការ	11.070	1.640	3.690	5.740	11.070
1315	អភិវឌ្ឍន៍ធនធានមនុស្ស	242	98	78	66	242
	ក្រសួងមហាផ្ទៃ	1.189.324	91.291	176.710	179.621	447.622
731	សាងសង់សាលាឃុំ-សង្កាត់	93.070	3.690	8.200	26.650	38.540
506	កែទម្រង់រដ្ឋបាល	92.250	5.018	22.550	17.630	45.198
1394	ពង្រឹងអភិបាលកិច្ចមូលដ្ឋាន	43.050	3.280	2.050		5.330
1395	កម្មវិធីសិទ្ធិកុមារ	5.945	1.189	1.189		2.378
1396	កម្មវិធីល្អ	58.630	5.330		4.100	9.430
1397	ទ្រទ្រង់ជីវភាពរបស់ប្រជាជនតំបន់បឹងទន្លេសាប	80.770	4.100			4.100
1398	គ្រប់គ្រងធនធានធម្មជាតិ និងកែលម្អជីវភាពរស់នៅ	79.130	4.100		4.100	8.200
1399	គម្រោងអភិបាលកិច្ចល្អ	45.100	4.100			4.100
1400	អភិវឌ្ឍន៍មូលដ្ឋានខេត្តសៀមរាប	61.500	4.100			4.100
1401	គាំទ្រវិមជ្ឈការ និងវិសហមជ្ឈការ	137.760				
598	សាងសង់សាលាខេត្ត-សាលាស្រុក	66.010	1.025	10.250	10.250	21.525
1339	ជួសជុល និងសាងសង់ពន្ធនាគារ ខេត្ត-រាជធានី	143.500	3.661	8.200	10.250	22.111
1332	សាងសង់សាលាបណ្តុះបណ្តាលរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ	3.809	1.267	1.271	1.271	3.809
1331	សាងសង់អគារទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ	12.300	1.230	4.100	6.970	12.300
1445	បណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិ	61.500	8.200	24.600	28.700	61.500
1550	សាងសង់សាលាបណ្តុះបណ្តាលប៉ូលីស ភូមិភាគ-ស្នងការ-សាលាភេរវកម្ម	205.000	41.000	94.300	69.700	205.000
	ក្រសួងផែនការ	15.068	6.376	3.916	2.686	12.977
1018	អង្កេតកម្លាំងពលកម្ម	492	164	164	164	492
1019	សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់	615	205	205	205	615
1020	សន្ទស្សន៍ថ្លៃផលិតករ និងផ្សេងៗ	554	185	185	185	554
[illegible]	[illegible]ក្រៅផ្លូវការ	923	308	308	308	923
[illegible]	បណ្តុះ[illegible]ាលការងារស្ថិតិ និងអភិវឌ្ឍន៍	2.255	410	1.435	205	2.050
[illegible]	ជួសជុល[illegible]ផែនការនៅតាមបណ្តាខេត្ត-រាជធានី ចំនួន ៤	2.460	1.230	615	615	2.460

ប្រភព: ទិន្នន័យពីក្រសួង-ស្ថាប័ននានា។ ប្រភពព័ត៌មាន:មូលដ្ឋានទិន្នន័យកម្មវិធីវិនិយោគសាធារណៈ ក្រសួងផែនការ

ការគ្រប់គ្រងឆ្នាំ ២០១០

តារាង "គ២"

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតាៈលានរៀល

លេខគម្រោង	ឈ្មោះគម្រោង	តំលៃគម្រោង	កម្រិតមូលវិនិយោគចែកតាមឆ្នាំ			
			២០១០	២០១១	២០១២	សរុប ៣ ឆ្នាំ
1349	អង្កេតហិរញ្ញវត្ថុកសិកម្មមិនរៀបរយ	123	41	41	41	123
1345	អង្កេតផលិតផលឧស្សាហកម្ម និងសន្ទស្សន៍ថ្លៃ	246	82	82	82	246
1347	អង្កេតមិនមែនសេដ្ឋកិច្ច	3.936	1.640	205	205	2.050
1346	សន្ទស្សន៍មុខទំនិញកសិកម្ម	246	82	82	82	246
1388	អង្កេតពីការលក់រាយ និងសន្ទស្សន៍ថ្លៃ	246	82	82	82	246
1343	ប្រមូល និងវិភាគទិន្នន័យរដ្ឋបាលផ្នែកស្ថិតិសេដ្ឋកិច្ច	923	308	308	308	923
1581	បញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនៅកម្ពុជា	2.050	1.640	205	205	2.050
ក្រសួងយុត្តិធម៌		**47.318**	**8.200**	**18.278**	**7.790**	**34.268**
61	ពង្រឹងហេដ្ឋារចនាសម្ព័ន្ធនៃអគារតុលាការ	19.614	4.100	12.128	1.640	17.868
1408	សាងសង់អគារតុលាការខេត្ត-រាជធានី	27.704	4.100	6.150	6.150	16.400
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា		**235.033**	**75.534**	**77.916**	**70.356**	**223.807**
1310	កម្មវិធីស្តារនីតិសម្បទា និងសមាហរណកម្មកុមារទំនាស់នឹងច្បាប់ និងប្រើប្រាស់គ្រឿងញៀនដោយបំពាននៅតាមមជ្ឈមណ្ឌល និងពន្ធនាគារ	2.300	738	697	697	2.132
1495	សាងសង់ភូមិកុមារ អេស អូ អេស នៅខេត្តក្រចេះ ព្រៃវែង ព្រះសីហនុ	36.900	6.150	16.400	14.350	36.900
1491	សាងសង់មជ្ឈមណ្ឌលយុវនីតិសម្បទា ខេត្តបាត់ដំបង សៀមរាប កំពង់ធំ ព្រះសីហនុ និងបោមចៅ	8.200	4.920	1.640	1.640	8.200
1481	សាងសង់ការិយាល័យសង្គមកិច្ចស្រុកទាំង ១៩០ ស្រុក	15.375	8.200	2.050	4.100	14.350
1482	សាងសង់វិទ្យាស្ថានជាតិសង្គមកិច្ច	6.806	1.726	1.722	1.759	5.207
1488	សាងសង់មជ្ឈមណ្ឌលជាតិនៃជនពិការ	7.290	1.726	1.722	1.759	5.207
1500	សាងសង់មជ្ឈមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះ ដោយសារការជួញដូរមនុស្ស កោះរំដួល	656	250	209	189	648
1498	សាងសង់មណ្ឌលសំចត និងទទួលជនរងគ្រោះ ដោយសារការជួញដូរមនុស្ស និងដោយប្រការផ្សេងៗ នៅខេត្តបន្ទាយមានជ័យ និងស្វាយរៀង	2.255	1.025	410	410	1.845
1486	និរន្តរភាពមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាទាំង ១១ កន្លែង	54.702	2.050	26.441	22.374	50.865
1489	សាងសង់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ គៀនឃ្លាំង	2.993	1.640	820	410	2.870
1499	សាងសង់មជ្ឈមណ្ឌលសង្គមកិច្ចរាជធានីភ្នំពេញ	529	205	205	119	529
1054	សាងសង់អគារស្នាក់នៅរបស់កុមារ ខេត្តកោះកុង	103	41	57		98
[illegible]	[illegible]សង់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ	11.275	2.050	2.050	6.150	10.250
[illegible]	[illegible] និងអគារវិឡូនីលំនៅដ្ឋានសហគមន៍ក្រីក្រ នៅរាជធានីភ្នំពេញ	5.207	1.763	1.763	1.230	4.756
1485	សាងសង់អគារបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល	66.092	34.850	18.450	12.300	65.600

សំគាល់ៈ ដកស្រង់ចេញពីក្រសួង-ស្ថាប័ននានា ។ ប្រភពព័ត៌មានៈទិន្នន័យនៃកម្មវិធីវិនិយោគសាធារណៈ ក្រសួងផែនការ

ការគ្រប់គ្រងឆ្នាំ ២០១០

តារាង "គ២"

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា: លានរៀល

លេខគម្រោង	ឈ្មោះគម្រោង	តំលៃគម្រោង	កម្រិតខ្ទង់វិនិយោគចែកតាមឆ្នាំ			
			២០១០	២០១១	២០១២	សរុប ៣ ឆ្នាំ
1484	សាងសង់ផ្ទះ និងភូមិអភិវឌ្ឍន៍អតីតយុទ្ធជន នៅពោធិ៍សាត់ បាត់ដំបង កំពង់ធំ និងកំពង់ចាម	14.350	8.200	3.280	2.870	14.350
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ		75.178	6.294	23.411	35.363	65.067
597	សាងសង់ពហុព្យាបាល និងមន្ទីរពិសោធន៍	2.895	1.312	410	410	2.132
894	ការបង្កើតប្រព័ន្ធព័ត៌មានទីផ្សារការងារ	6.150	205	4.100	1.845	6.150
983	ផ្តល់សមធម៌ក្នុងការចូលរៀនផ្នែកអប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ	41.000	2.050	10.250	28.700	41.000
984	សាងសង់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-រាជធានី	11.808	820	820	820	2.460
985	សាងសង់អគារសិក្សានៅវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ	6.150	410	4.100	1.435	5.945
1298	គម្រោងបញ្ច្រាបយេនឌ័រនៅក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	1.025	185	451	390	1.025
1534	បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ខេត្តព្រះវិហារ និងមណ្ឌលគិរី	6.150	1.312	3.280	1.763	6.355
ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច		15.961	2.989	3.526	5.059	11.574
1570	អភិបាលកិច្ចមូលដ្ឋាន	10.500	2.579	1.886	1.779	6.244
740	ពង្រឹងគុណភាពការងារអធិការកិច្ច	5.461	410	1.640	3.280	5.330
ក្រសួងបរិស្ថាន		436.277	10.291	79.593	97.150	187.034
612	ការគ្រប់គ្រងបរិស្ថានបឹងទន្លេសាប	79.376				
1025	ការរៀបចំរបាយការណ៍លើកទី ២ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ	1.661				
1026	គម្រោងសកម្មភាពសម្រាប់អនុវត្តក្របខ័ណ្ឌជីវសុវត្ថិភាព	4.510				
1280	ការគ្រប់គ្រងតំបន់អភិរក្ស	16.400	2.050	1.845		3.895
63	បង្កើតវិទ្យាស្ថានស្រាវជ្រាវ និងការគ្រប់គ្រងបំពុលបរិស្ថាន	39.827	2.460	2.050	20.500	25.010
387	បង្កើនសមត្ថភាពលើការគ្រប់គ្រងកាកសំណល់រាវ	5.945	1.804	1.845	1.845	5.494
390	ពង្រឹងសមត្ថភាពបរិស្ថាន EIA	16.093	820	3.690	8 200	12.710
452	វគ្គបណ្តុះបណ្តាលការងារអប់រំបរិស្ថាន	2.165	697	463	1.005	2.165
777	ការគ្រប់គ្រង និងអភិរក្សជីវចម្រុះអាងទន្លេមេគង្គ	118.039	820	32.800	24 600	58.220
778	ការគ្រប់គ្រងសំណល់	129.519	820	24.600	32.800	58.220
779	ពង្រឹងសមត្ថភាពស្តីពីដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាន	22.743	820	12.300	8.200	21.320
ក្រសួងទេសចរណ៍		260.535	16.679	42.976	85.223	144.878
[illegible]	គម្រោងអភិវឌ្ឍន៍ទេសចរណ៍មេគង្គ	38.983				

សម្គាល់: ចំនួនទឹកប្រាក់ស្នើពីក្រសួង-ស្ថាប័ននានា ។ ប្រភពព័ត៌មាន: មូលដ្ឋានទិន្នន័យនៃកម្មវិធីវិនិយោគសាធារណៈ ក្រសួងផែនការ

ការគ្រប់គ្រងឆ្នាំ ២០១០

តារាង "គ២"

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា:លានរៀល

លេខគម្រោង	ឈ្មោះគម្រោង	តម្លៃគម្រោង	កម្រិតវិនិយោគចែកតាមឆ្នាំ			
			២០១០	២០១១	២០១២	សរុប ៣ ឆ្នាំ
1566	សាងសង់ស្ថានីយ៍ចំណតទេសចរណ៍នៅតំបន់ត្រីកោណអភិវឌ្ឍន៍ ខេត្តស្ទឹងត្រែង មណ្ឌលគិរី រតនគិរី	3.075	1.230	1.230	615	3.075
56	អភិវឌ្ឍន៍តំបន់ទេសចរណ៍ទី ២	27.060	1.230	5.330	20.500	27.060
72	សាងសង់មន្ទីរទេសចរណ៍	15.580	820	4.100	4.100	9.020
968	សមាហរណកម្មបច្ចេកវិទ្យាព័ត៌មានទេសចរណ៍	1.107	1.107			1.107
969	សាងសង់វិទ្យាស្ថានទេសចរណ៍ជាតិ (CNIT)	14.350	820	4.920	6.970	12.710
971	សង់មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍	36.900	2.050	4.100	8.200	14.350
970	កាត់បន្ថយភាពក្រីក្រក្នុងបរិបទនៃនិរន្តរភាពក្នុងវិស័យទេសចរណ៍	90.200	2.050	10.250	32.800	45.100
1409	អភិវឌ្ឍន៍រមណីយដ្ឋានស្ទឹងជីនិត កំពង់ធំ	5.740	1.078	3.690	693	5.461
1410	អភិវឌ្ឍន៍រមណីយដ្ឋានរមនា១ មណ្ឌលគិរី	2.669	1.078	898	693	2.669
1411	កែលម្អរមណីយដ្ឋានផ្ទះតាម៉ុក ឧត្តរមានជ័យ	615	205	205	205	615
1412	អភិវឌ្ឍន៍រមណីយដ្ឋានទឹកជ្រោះប៊ូស្រា មណ្ឌលគិរី	2.989	1.087	1.025	877	2.989
1413	អភិវឌ្ឍន៍រមណីយដ្ឋានទឹកជ្រោះមនោរម្យ មណ្ឌលគិរី	1.263	619	361	283	1.263
1414	អភិវឌ្ឍន៍រមណីយដ្ឋានហ្លួងព្រះស្ដេចកន កំពង់ចាម	17.765	2.050	6.150	9.020	17.220
1415	អភិវឌ្ឍន៍រមណីយដ្ឋានប្រាសាទនគរបាជ័យ កំពង់ចាម	2.239	1.255	718	267	2.239
ក្រសួងកិច្ចការនារី		19.270	5.346	353	426	6.125
1087	កម្មវិធីពង្រឹងសហគមន៍ដើម្បីប្រយុទ្ធនឹងជំងឺគ្រុនចាញ់	2.050	426	353	426	1.205
1089	គម្រោងលើកកម្ពស់សមធម៌យេនឌ័រ	8.200	4.920			4.920
1090	មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី	9.020				
ទីស្តីការគណៈរដ្ឋមន្ត្រី		376.790	30.750			30.750
1437	សាងសង់មជ្ឈមណ្ឌលព័ត៌មានវិទ្យា	86.100	18.450			18.450
1438	សាងសង់ទីស្តីការគណៈរដ្ឋមន្ត្រី	151.290				
1439	ពង្រឹងសមត្ថភាពប្រព័ន្ធបច្ចេកវិទ្យា	20.500	12.300			12.300
1440	សាងសង់ប្រព័ន្ធព័ត៌មានរដ្ឋបាលខេត្ត-រាជធានី	118.900				
រាជធានីភ្នំពេញ		1 659.735	43.112	69.372	74.653	187.136
1297	ជួសជុលផ្សារថ្មីឡើងវិញ	18.450	3.899			3.899
792	គម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយ លូ ក្នុងរាជធានីភ្នំពេញ	82.943	8.696			8.696
[illegible]	[illegible]កែលម្អប្រព័ន្ធប្រមូលសម្រាមក្នុងរាជធានីភ្នំពេញ	60.012	10.836	20.500	25.477	56.814
[illegible]	កែលម្អ[illegible]ស្ពានទៅក្នុងរាជធានីភ្នំពេញ	139.851	2.460	21.402	39.729	63.591
[illegible]	លើកកម្ពស់[illegible]ភាពផ្លូវក្នុងរាជធានីភ្នំពេញ	38.712	820	4.100	2.050	6.970

ប្រភព: ជំពូកទិន្នន័យពីក្រសួង-ស្ថាប័ននានា ។ ប្រភពព័ត៌មាន:ទិន្នន័យនៃកម្មវិធីវិនិយោគសាធារណៈក្រសួងផែនការ

ការគ្រប់គ្រងឆ្នាំ ២០១០

តារាង "គ២"

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា:លានរៀល

លេខគម្រោង	ឈ្មោះគម្រោង	តំលៃគម្រោង	កម្រិតទុនវិនិយោគចែកតាមឆ្នាំ			
			២០១០	២០១១	២០១២	សរុប ៣ ឆ្នាំ
1564	អភិវឌ្ឍន៍ប្រព័ន្ធបំភ្លឺសាធារណៈថ្មីក្នុងរាជធានីភ្នំពេញ	287.000	12.300	18.450	2.066	32.816
780	ជួសជុលផ្សារកណ្តាល-ផ្សារចាស់ក្នុងរាជធានីភ្នំពេញ	32.767	4.100	4.920	5.330	14.350

7/54 h.

ការគ្រប់គ្រងឆ្នាំ ២០១០

តារាងភ្ជាប់តាម "គ៣"

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

គំរោងឥណទាន និង ឥណទានភ្ជាប់សន្យាឆ្នាំ ២០១០

ឯកតា :លានរៀល

ក្រសួង ស្ថាប័ន	គំរោង ២០១០	សរុបឥណទានភ្ជាប់សន្យាឆ្នាំ ២០១០ * (1)+(2)+(3)*10%	កំពុងដំណើរការ (1)	ព្រមព្រៀងរួច (2)	កំពុងចរចា (3)
សរុបរួម	3.121.203	2.576.300	2.515.801		605.402
វិស័យរដ្ឋបាលទូទៅ	317.836	221.700	211.179		106.657
ទីស្តីការគណៈរដ្ឋមន្ត្រី	30.750	30.800	30.750		
ក្រសួងមហាផ្ទៃ	134.402	56.100	47.503		86.900
- រដ្ឋបាលកណ្តាល	91.291	40.500	34.907		56.383
- រាជធានី-ខេត្ត	43.112	15.600	12.595		30.516
ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច	2.989	2.600	2.579		410
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	135.120	130.800	130.347		4.772
ក្រសួងផែនការ	6.376	600			6.376
ក្រសួងយុត្តិធម៌	8.200	800			8.200
វិស័យសង្គមកិច្ច	831.804	729.500	718.037		113.767
ក្រសួងព័ត៌មាន	13.838	8.300	7.698		6.150
ក្រសួងសុខាភិបាល	502.517	502.500	502.517		
ក្រសួងអប់រំ យុវជន និង កីឡា	201.577	194.400	193.549		8.028
ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ	12.825	1.300			12.825
ក្រសួងបរិស្ថាន	10.291	2.900	2.050		8.241
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា	75.534	13.800	6.888		68.646
ក្រសួងធម្មការ និង សាសនា	3.583	400			3.583
ក្រសួងកិច្ចការនារី	5.346	5.300	5.346		
ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ	6.294	600			6.294
វិស័យសេដ្ឋកិច្ច	1.971.563	1.825.100	1.586.585		384.978
រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	11.337	1.100			11.337
ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល	180.031	149.000	145.550		34.481
ក្រសួងពាណិជ្ជកម្ម	23.645	12.900	11.685		11.960
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	239.735	105.300	90.364		149.371
ក្រសួងអភិវឌ្ឍន៍ជនបទ	86.092	52.100	48.306		37.786
ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍	56.535	46.900	45.875		10.660
ក្រសួងសាធារណការ និង ដឹកជញ្ជូន	1.041.790	970.400	962.438		79.351
ក្រសួងទេសចរណ៍	16.679	2.800	1.230		15.449
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់	39.442	39.300	39.237		205
ក្រសួងធនធានទឹក និង ឧតុនិយម	276.279	245.300	241.900		34.379

[illegible] (*) [illegible] ។

ការគ្រប់គ្រងឆ្នាំ ២០១០
តារាង "ឃ"
ចំណាយជាមូលធននៃថវិកាថ្នាក់ជាតិរបស់រដ្ឋ
ឥណទានក្ងាប់សន្យា និង ឥណទានទូទាត់

ឯកតា:លានរៀល

ក្រសួង_ស្ថាប័ន	សរុប ឥណទាន ក្ងាប់សន្យា	សរុប ឥណទាន ទូទាត់	វិនិយោគសាធារណៈដោយ ហិរញ្ញប្បទានក្នុងប្រទេស			វិនិយោគសាធារណៈដោយ ហិរញ្ញប្បទានក្រៅប្រទេស		ការទូទាត់ ប្រាក់កម្ចី
			ឥណទានក្ងាប់សន្យា=ឥណទានទូទាត់			ឥណទាន ក្ងាប់សន្យា	ឥណទាន ទូទាត់	ឥណទានក្ងាប់សន្យា= ឥណទានទូទាត់
			គំរោង វិនិយោគ	បដិភាគ វិនិយោគ	មូលនិធិ ទ្រទ្រង់ថវិកា			
សរុបរួមចំណាយ	3.847.300,0	3.271.000,0	515.000,0	198.000,0	408.000,0	2.576.300,0	2.000.000,0	150.000,0
ក. វិស័យរដ្ឋបាលទូទៅ	221.700,0	172.200,0				221.700,0	172.200,0	
០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី	30.800,0	23.900,0				30.800,0	23.900,0	
០៧. ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ	56.100,0	43.500,0				56.100,0	43.500,0	
- រដ្ឋបាលកណ្តាល	40.500,0	31.400,0				40.500,0	31.400,0	
- រាជធានី-ខេត្ត	15.600,0	12.100,0				15.600,0	12.100,0	
០៨. ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច	2.600,0	2.000,0				2.600,0	2.000,0	
១០. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	130.800,0	101.700,0				130.800,0	101.700,0	
១៤. ក្រសួងផែនការ	600,0	500,0				600,0	500,0	
២៦. ក្រសួងយុត្តិធម៌	800,0	600,0				800,0	600,0	
គ. វិស័យសង្គមកិច្ច	729.500,0	566.300,0				729.500,0	566.300,0	
១១. ក្រសួងព័ត៌មាន	8.300,0	6.400,0				8.300,0	6.400,0	
១២. ក្រសួងសុខាភិបាល	502.500,0	390.100,0				502.500,0	390.100,0	
១៦. ក្រសួងអប់រំ យុវជន និង កីឡា	194.400,0	150.900,0				194.400,0	150.900,0	
១៨. ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ	1.300,0	1.000,0				1.300,0	1.000,0	
១៩. ក្រសួងបរិស្ថាន	2.900,0	2.300,0				2.900,0	2.300,0	
២១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា	13.800,0	10.700,0				13.800,0	10.700,0	
២៣. ក្រសួងធម្មការ និង សាសនា	400,0	300,0				400,0	300,0	
២៤. ក្រសួងកិច្ចការនារី	5.300,0	4.100,0				5.300,0	4.100,0	
៣២. ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ	600,0	500,0				600,0	500,0	
ឃ. វិស័យសេដ្ឋកិច្ច	1.975.100,0	1.611.500,0	350.000,0			1.625.100,0	1.261.500,0	
០៥.៣. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	1.100,0	900,0				1.100,0	900,0	
១៣. ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល	149.000,0	115.700,0				149.000,0	115.700,0	
១៥. ក្រសួងពាណិជ្ជកម្ម	12.900,0	10.000,0				12.900,0	10.000,0	
១៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	105.300,0	81.700,0				105.300,0	81.700,0	
២០. ក្រសួងអភិវឌ្ឍន៍ជនបទ	142.100,0	130.400,0	90.000,0			52.100,0	40.400,0	
២២. ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍	46.900,0	36.400,0				46.900,0	36.400,0	
២៤. ក្រសួងសាធារណការ និង ដឹកជញ្ជូន	1.160.400,0	943.300,0	190.000,0			970.400,0	753.300,0	
២៧. ក្រសួងទេសចរណ៍	2.800,0	2.200,0				2.800,0	2.200,0	
២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់	39.300,0	30.500,0				39.300,0	30.500,0	
២៩. ក្រសួងធនធានទឹក និង ឧតុនិយម	315.300,0	260.400,0	70.000,0			245.300,0	190.400,0	

ទំព័រ ១/២

Ksl

ការគ្រប់គ្រងឆ្នាំ ២០១០

តារាង "ឃ"

ចំណាយជាមូលធននៃថវិកាទូទៅរបស់រដ្ឋ

ឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់

ឯកតា:លានរៀល

ក្រសួង-ស្ថាប័ន	សរុប ឥណទានភ្ជាប់សន្យា	សរុប ឥណទានទូទាត់	វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស			វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស		ការទូទាត់ប្រាក់កម្ចី
			ឥណទានភ្ជាប់សន្យា=ឥណទានទូទាត់					
			គំរោងវិនិយោគ	បដិភាគវិនិយោគ	មូលនិធិទ្រទ្រង់ជីវភាព	ឥណទានភ្ជាប់សន្យា	ឥណទានទូទាត់	ឥណទានភ្ជាប់សន្យា= ឥណទានទូទាត់
៩៩. ចំណាយមិនទាន់បែងចែក	921.000,0	921.000,0	165.000,0	198.000,0	408.000,0			150.000,0
- ការទូទាត់ប្រាក់កម្ចី	150.000,0	150.000,0						150.000,0
- គំរោងវិនិយោគ	165.000,0	165.000,0	165.000,0					
- បដិភាគមូលធន	198.000,0	198.000,0		198.000,0				
- វិនិយោគដោយមូលនិធិទ្រទ្រង់ជីវភាព	408.000,0	408.000,0			408.000,0			

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានបញ្ចប់មុខងារពីទីប្រឹក្សា និងជំនួយការសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម	**ទេព្យ ទន**	ទីប្រឹក្សា
២-ឯកឧត្តម	**ទេព្យ ចាន់ម៉ារ៉ាញ**	ជំនួយការ
៣-ឯកឧត្តម	**ចាប ពៅ**	ជំនួយការ

មាត្រា២ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រ.ល. ០៩១២ៃ. ១២០០

លេខ: ១១២៥ ច.ល
ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ រាជធានីភ្នំពេញ ថ្ងៃទី ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
... កេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ជូនចំពោះ :

១-លោក **យិន ម៉ាលីណា**

២-លោក **ខោល យុទ្ធលី**

- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ជូនចំពោះ :

១-លោក **ធន ស៊ុផា**

២-លោក **ប្រាក់ សំអឿន**

៣-លោក **សុខ ចំរើន**

៤-លោក **ឈិន សេងចួន**

៥-លោក **ស៊ី ថារិន**

៦-លោក **នី គឹមសាន**

៧-លោក **យ៉ាំ ម៉េងស៊ាន**

៨-លោក **ម្រេង សុភាព**

៩-លោក **សេង សីលា**

៣៧.០៩១២.១២០១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ:១០៩៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឃុន ជិនកេន

ព្រះរាជក្រឹត្យ

យើង

នស/រកត/១២០៩/១១៧៦

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

១-លោកវរសេនីយ៍ទោ អ៊ុច ម៉ុនថន អត្តលេខ ០១០៧០

២-លោកវរសេនីយ៍ត្រី សុខ អ៊ុន អត្តលេខ ០៩៣៧៩

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៩១២.១២០៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ:១០៩៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម :

ក-ថ្នាក់ឧត្តមសេនីយ៍ទោ :

១-លោកឧត្តមសេនីយ៍ត្រី **ឌួន ពិសី** អត្តលេខ ០៤៥៤
២-លោកឧត្តមសេនីយ៍ត្រី **ធន សាម៉ន** អត្តលេខ ០១៨៤
៣-លោកឧត្តមសេនីយ៍ត្រី **ចេង សុវណ្ណា** អត្តលេខ ០១៦៤ ។

ខ-ថ្នាក់ឧត្តមសេនីយ៍ត្រី :

១-លោកវរសេនីយ៍ឯក **ស៊ូ ម៉ិនធឿន** អត្តលេខ ០២៤០
២-លោកវរសេនីយ៍ឯក **ចិន ចាន** អត្តលេខ ០១៣៦៥
៣-លោកវរសេនីយ៍ឯក **ជា ឡាយ** អត្តលេខ ០១៣៨៦
៤-លោកវរសេនីយ៍ឯក **ឡាំ វណ្ណា** អត្តលេខ ០៨០៣
៥-លោកវរសេនីយ៍ឯក **ព្រំ ឧចប៉ូវធឿន** អត្តលេខ ០៨៤៥
៦-លោកវរសេនីយ៍ឯក **ហាប់ សាឃឿន** អត្តលេខ ០៦២៩
៧-លោកវរសេនីយ៍ឯក **និត្យ សំអាន** អត្តលេខ ០៧៤៦

៨-លោកវរសេនីយ៍ឯក ម៉ៅ សុខឡូនា អត្តលេខ ០៦៩០
៩-លោកវរសេនីយ៍ឯក សោម ឡេង អត្តលេខ ០១៥២៧
១០-លោកវរសេនីយ៍ឯក ស៊ុន ធុស្សី អត្តលេខ ០៦៤៩
១១-លោកវរសេនីយ៍ឯក សែ ម៉ារ៉ា អត្តលេខ ០០៨៧
១២-លោកវរសេនីយ៍ឯក គី សុផន អត្តលេខ ០៧៨២
១៣-លោកវរសេនីយ៍ឯក ស៊ុន រ៉ូ អត្តលេខ ០១៤៨៦
១៤-លោកវរសេនីយ៍ឯក សុខ ទាសនា អត្តលេខ ០១៤១១
១៥-លោកវរសេនីយ៍ឯក នូ សទ្ធា អត្តលេខ ០៥៥៥
១៦-លោកវរសេនីយ៍ឯក រាជ សុខុន អត្តលេខ ០៤៦១
១៧-លោកវរសេនីយ៍ឯក មុន្នី រតនា អត្តលេខ ០២៧០
១៨-លោកវរសេនីយ៍ឯក ជុំ ហេង អត្តលេខ ០៦២២១
១៩-លោកវរសេនីយ៍ឯក ឡាយ សមត្ថា អត្តលេខ ០៩១០
២០-លោកវរសេនីយ៍ឯក នៅ សុផា អត្តលេខ ០១៣៨៣ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩១២.១២០៣

លេខ:១០៩៩ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ [illegible] ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក លី គួយ

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៩១២.១២០៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩

លេខៈ ១១១០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ប៊ិន ឈិន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែល ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៩០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **តោ ពន្លក** អត្តលេខ០២១៩៤ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១.ធ.០៩១២.១៧០៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ:១១១១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី ... រដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង ឯកឧត្តម ឧត្តមសេនីយ៍ទោ **អុន ឈន** អត្តលេខ ០០៥៩ ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនឯកឧត្តម ឧត្តមសេនីយ៍ទោ **អុន ឈន** អត្តលេខ ០០៥៩ នាយនគរបាលជាតិជាន់ខ្ពស់ នៃ ក្រសួងមហាផ្ទៃ ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹង ព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩១៤.១៧០៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩

លេខ:១១០០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៧១

ស្តីពី

ការតែងតាំងសមាសភាពរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងការកែសម្រួលឋានៈរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថនរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពិសិដ្ឋប្រាជ្ញាញាណមហាក្សត្រ
ខេមរាជនា សម្ពោធភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានយល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៩/៩៤៣ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការកែសម្រួល និងការធ្វើនិយតភាព ការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបថ្វាយបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងសមាសភាពរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដូចតទៅ ៖

- ឯកឧត្តម លឹម គានហោ	រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម	ប្រធាន
- ឯកឧត្តម ម៉ុក ម៉ារ៉េត	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន	អនុប្រធាន
- ឯកឧត្តម ត្រាំ អ៊ីវតឹក	រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន	អនុប្រធាន
- ឯកឧត្តម ស៊ិន នីនី		អនុប្រធានអចិន្ត្រៃយ៍ មានឋានៈស្មើរដ្ឋមន្ត្រី
- ឯកឧត្តម ចក់ ឡេង	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
- ឯកឧត្តម អ៊ុច បូរិទ្ធ	រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
- ឯកឧត្តម សក់ សេដ្ឋា	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
- ឯកឧត្តម ម៉ុន ហ៊ាន	រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
- ឯកឧត្តម ហែម កុលបុត្រ	រដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
- ឯកឧត្តម ជៅ ទ្រី	រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
- ឯកឧត្តម ម៉ុម ស៊ីបុន	រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក

- ឯកឧត្តម សាត សាមី	រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
- ឯកឧត្តម ហ៊ូ តាំងអេង	រដ្ឋលេខាធិការក្រសួងផែនការ	សមាជិក
- ឯកឧត្តម សួស គង់	រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
- ឯកឧត្តម ឈឹម កែលាង	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
- ឯកឧត្តម គោស៊ុំ សារឿត	រដ្ឋលេខាធិការក្រសួងទេសចរណ៍	សមាជិក
- ឯកឧត្តម អ៊ូ ប៊ុនឡុង	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
- លោកជំទាវ ច័ន្ទ សូរីយ៍	រដ្ឋលេខាធិការក្រសួងកិច្ចការនារី	សមាជិក
- ឯកឧត្តម ពៅ សាមី	អគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ	សមាជិក
- ឯកឧត្តម សុខ ចិន្តា	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា	សមាជិក
- ឯកឧត្តម សាយ សំអាល់	អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការអាជ្ញាធរទន្លេសាប	សមាជិក

មាត្រា ២: ត្រូវបានកែសម្រួលឋានៈរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដូចតទៅ :

១- ឯកឧត្តម ពេជ ឌុន អគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ**

២- ឯកឧត្តម តែ ណាវុធ អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ**អនុរដ្ឋលេខាធិការ**

៣- ឯកឧត្តម គល់ ទឡ្ហនា អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ**អនុរដ្ឋលេខាធិការ**

៤- ឯកឧត្តម សូ សុភ័ន្ធ អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ**អនុរដ្ឋលេខាធិការ**

៥- ឯកឧត្តម ទ៉ាត់ បុត្តកុសល អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាមានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

៦- ឯកឧត្តម អានពេជ្រហត្ថជា អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាមានឋានៈស្មើ**អនុរដ្ឋលេខាធិការ**

មាត្រា ៣ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

៣រល.០៩១២.១២០៧

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩

លេខៈ ១១០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២១៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក។

មាត្រា ២.-

ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក ត្រូវរៀបចំឱ្យមានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរៀងៗខ្លួន ដើម្បីជួយសិក្សានិងផ្តល់យោបល់ដល់ក្រុមប្រឹក្សានិងគណៈអភិបាលរបស់ខ្លួន លើបញ្ហាទាក់ទងនឹងការងារផែនការ ថវិកា ការសម្របសម្រួលកិច្ចការនានារបស់ក្រុមប្រឹក្សា ជាមួយមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងក្រុមប្រឹក្សាប្រភេទផ្សេងទៀត និងបញ្ហាទាក់ទងនឹងមុខងារ ធនធានដែលបានប្រគល់ឬបានផ្ទេរប្រតិភូកម្មឱ្យក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក។

ជំពូកទី២

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត

ផ្នែកទី១

សមាសភាព និង តួនាទី ភារកិច្ច

មាត្រា ៣.-

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត មានសមាសភាពដូចខាងក្រោម :

- អភិបាលខេត្ត ជាប្រធាន
- អភិបាលរងខេត្ត០១រូប ជាអនុប្រធាន
- នាយករដ្ឋបាលសាលាខេត្ត ជាសមាជិកអចិន្ត្រៃយ៍
- សមាជិកក្រុមប្រឹក្សាខេត្តយ៉ាងតិច០២រូប ជាសមាជិក
- ប្រធានមន្ទីរ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលដែលប្រចាំនៅខេត្ត ជាសមាជិក

- នាយកទីចាត់ការទាំងអស់របស់សាលាខេត្ត ជាសមាជិក
- អភិបាលក្រុងនិងអភិបាលស្រុកទាំងអស់នៅក្នុងខេត្ត ជាសមាជិក
- តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំខេត្ត០២រូប ជាសមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សាខេត្ត០១រូប ជាសមាជិក

សមាសភាពអនុប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត ត្រូវស្នើដោយអភិបាលខេត្ត។

តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំខេត្ត០២រូបត្រូវចាត់តាំងដោយគណៈកម្មាធិការប្រតិបត្តិនៃសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំខេត្ត។ តំណាងទាំងពីររូបនេះត្រូវមានស្ត្រីមួយរូប។

ក្រុមប្រឹក្សាខេត្ត ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត។ សេចក្តីសម្រេចនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាខេត្ត។

មាត្រា ៥.-

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត មានតួនាទី ភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលខេត្ត លើកិច្ចការសំខាន់ៗដូចខាងក្រោម :

ក. ផែនការអភិវឌ្ឍ និងថវិកា

- ការដាក់បញ្ចូលផែនការអភិវឌ្ឍនិងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលដែលបានផ្តល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខេត្ត
- សេចក្តីព្រាងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងការធ្វើបច្ចុប្បន្នភាព
- សេចក្តីព្រាងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខេត្ត
- សេចក្តីព្រាងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងការធ្វើបច្ចុប្បន្នភាព
- ការងារហិរញ្ញវត្ថុនិងថវិការបស់ក្រុមប្រឹក្សាខេត្ត
- សេចក្តីព្រាងគម្រោងវិភាជន៍មូលនិធិវិនិយោគខេត្ត ដើម្បីគាំទ្រដល់កម្មវិធីនានារបស់ខេត្ត
- កៀរគរការគាំទ្រពីអ្នកពាក់ព័ន្ធនានាដល់គម្រោងវិនិយោគខេត្ត

- របាយការណ៍រីកចម្រើននានាទាក់ទងដល់ការងារផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងថវិការបស់ក្រុមប្រឹក្សាខេត្ត។

ខ. សម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាខេត្តជាមួយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានា

- កិច្ចសហប្រតិបត្តិការ ការពិគ្រោះយោបល់ និងការសម្របសម្រួលកិច្ចការនានារបស់ក្រុមប្រឹក្សាខេត្ត ជាមួយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ន
- សម្របសម្រួលការផ្តល់សេវានិងការអភិវឌ្ឍដែលផ្តល់ដោយក្រសួង ស្ថាប័ន ឬដោយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ន ដើម្បីឆ្លើយតបតម្រូវការរបស់មូលដ្ឋាន
- ការសម្របសម្រួលភាពមិនចុះសម្រុងគ្នារវាងកិច្ចការរបស់ក្រុមប្រឹក្សាខេត្តជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញនានា
- ការផ្តល់អនុសាសន៍ដល់ក្រសួង ស្ថាប័ននានា ដើម្បីកែលម្អការផ្តល់សេវា និងការអភិវឌ្ឍស្របតាមតម្រូវការរបស់មូលដ្ឋាន។

គ. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាពខេត្ត

- ការរៀបចំយន្តការពិគ្រោះយោបល់និងការចូលរួមក្នុងដំណើរការអនុវត្តការងារនៃរដ្ឋបាលឯកភាពខេត្ត
- ការរៀបចំប្រព័ន្ធនិងនីតិវិធីបំពេញការងារ ព្រមទាំងទំនាក់ទំនងរបស់ទីចាត់ការនានានៃសាលាខេត្ត
- ការដោះស្រាយនូវភាពមិនចុះសម្រុងគ្នាក្នុងការអនុវត្តការងាររបស់ទីចាត់ការនានានៃសាលាខេត្ត។

ឃ. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់នៅក្នុងខេត្ត

- ការរៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត
- ការឆ្លើយតបចំពោះអនុសាសន៍ សំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត ក្នុងករណីដែលក្រុមប្រឹក្សាទាំងនោះមិនអាចដោះស្រាយបាន
- ការដោះស្រាយនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាក្រុង ឬ/និងក្រុមប្រឹក្សាស្រុក ឬ/និងក្រុមប្រឹក្សាឃុំ ឬ/និងក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត។

ង. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត

- ការរៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាដែលមាន

ព្រំប្រទល់ជាប់គ្នានិងក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត

- ការសម្រុះសម្រួលនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាដែលមានព្រំប្រទល់ជាប់គ្នានិងក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត។

ច. ការទទួលខុសត្រូវមុខងារ និងធនធាន

- វិធានការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារនិងធនធាន
- ការរៀបចំនូវលក្ខណសម្បត្តិនិងមធ្យោបាយដើម្បីទទួលនិងអនុវត្តមុខងារ និងធនធានថ្មីដែលបានប្រគល់ឬបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលខេត្ត
- ការផ្តួចផ្តើមស្នើឡើងនូវមុខងារនិងធនធានដែលគួរត្រូវបានប្រគល់ ឬបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលខេត្ត
- ការផ្តួចផ្តើមអំពីការធ្វើប្រតិភូកម្មនូវមុខងារនិងធនធានដល់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់
- ការវាយតម្លៃលើការអនុវត្តមុខងារនិងធនធានដែលស្ថិតក្រោមការទទួលខុសត្រូវនៃរដ្ឋបាលខេត្ត។

ក្រៅពីកិច្ចការខាងលើនេះ គណៈកម្មាធិការអាចទទួលអនុវត្តកិច្ចការផ្សេងទៀត តាមតម្រូវការនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ឬតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សារបស់ខ្លួន។

ផ្នែកទី២
របៀបរបបការងារ

មាត្រា ៥.-

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត ត្រូវជួបប្រជុំយ៉ាងតិចពីរខែម្តង។ កិច្ចប្រជុំអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការទាំងមូល។

សេចក្តីសម្រេចរបស់អង្គប្រជុំអាចយកជាការបាន លុះត្រាមានសម្លេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល។

ប្រធានគណៈកម្មាធិការ ជាអ្នកកោះប្រជុំនិងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។

គ្រប់កិច្ចប្រជុំរបស់គណៈកម្មាធិការ ត្រូវមានកំណត់ហេតុដែលរៀបចំដោយនាយករដ្ឋបាលសាលាខេត្ត និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

ផ្អែកតាមអនុក្រឹត្យនេះ គណៈកម្មាធិការអាចកំណត់អំពីរបៀបរបបប្រជុំ ការអនុម័តរបៀបរបបការងារជាក់ស្តែងនិងការបែងចែកភារកិច្ចដល់សមាជិកគណៈកម្មាធិការតាមការចាំបាច់។

មាត្រា ៦.-

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការ ដែលជានាយករដ្ឋបាលសាលាខេត្ត អភិបាលក្រុង អភិបាលស្រុក ប្រធានមន្ទីរ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលប្រចាំនៅខេត្ត និងនាយកទីចាត់ការនៃសាលាខេត្តអវត្តមាន សមាជិកនោះអាចចាត់តំណាងដែលមានសិទ្ធិសម្រេចជំនួសខ្លួនឱ្យចូលរួមប្រជុំគណៈកម្មាធិការបាន។

មាត្រា ៧.-

អភិបាលខេត្ត អាចស្នើឱ្យអភិបាលរងខេត្ត មន្ត្រី ទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធនានា ចូលរួមកិច្ចប្រជុំគណៈកម្មាធិការតាមការចាំបាច់។ អភិបាលរងខេត្ត មន្ត្រី ទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធទាំងនោះ អាចផ្តល់យោបល់នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការបាន ប៉ុន្តែពុំមានសិទ្ធិអនុម័តឡើយ។

មាត្រា ៨.-

កិច្ចប្រជុំនីមួយៗរបស់គណៈកម្មាធិការ ត្រូវមានរបៀបវារៈដែលបានត្រៀមរៀបចំជាមុន។

អភិបាលខេត្ត ដោយមាននាយករដ្ឋបាលសាលាខេត្តជាជំនួយការ ត្រូវរៀបចំរបៀបវារៈប្រជុំដោយផ្អែកតាម :

- តម្រូវការរបស់ក្រុមប្រឹក្សាខេត្ត
- តម្រូវការរបស់គណៈអភិបាលខេត្ត
- តម្រូវការរបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត
- សំណើរបស់សមាជិកយ៉ាងតិចមួយភាគបីនៃចំនួនសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត
- តម្រូវការនៃច្បាប់ឬលិខិតបទដ្ឋានគតិយុត្ត។

ផ្អែកតាមតម្រូវការនិងសំណើដូចខាងលើនេះ អភិបាលខេត្តត្រូវពិគ្រោះយោបល់នៅក្នុងគណៈអភិបាលរបស់ខ្លួន ចាត់ឱ្យទីចាត់ការមួយឬច្រើនដែលពាក់ព័ន្ធនៃសាលាខេត្ត ដើម្បីសិក្សារៀបចំឯកសារ បែបបទ នីតិវិធីនានាតាមរបៀបវារៈនីមួយៗ។

នាយករដ្ឋបាលសាលាខេត្ត ត្រូវដឹកនាំទីចាត់ការដែលពាក់ព័ន្ធនៅក្នុងសាលាខេត្ត សិក្សារៀបចំឯកសារ បែបបទ នីតិវិធីខាងលើនេះ ដោយសហការជាមួយមន្ទីរ អង្គភាព និងរដ្ឋបាលដែលពាក់ព័ន្ធនានាតាមការចាំបាច់។

មាត្រា ៩.-

ក្នុងការសិក្សា រៀបចំឯកសារ បែបបទ នីតិវិធីដូចមានចែងក្នុងមាត្រា៨ ខាងលើនេះ

នាយករដ្ឋបាលសាលាខេត្ត ត្រូវផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីកាគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់អនុវត្តច្បាប់ទាំងនេះ។

ក្រោយពេលរៀបចំឯកសារ បែបបទ នីតិវិធីតាមរបៀបវារៈនីមួយៗរួចហើយ នាយករដ្ឋបាលសាលាខេត្តត្រូវដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យ និងរៀបចំកោះប្រជុំគណៈកម្មាធិការ។

មាត្រា ១០.-

អភិបាលខេត្ត ដោយមាននាយករដ្ឋបាលសាលាខេត្តជាជំនួយការ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មាធិការ ដើម្បីដាក់ជូនក្រុមប្រឹក្សាខេត្តចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ឬដាក់ជូនគណៈអភិបាលខេត្តចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់គណៈអភិបាលខេត្ត។

មាត្រា ១១.-

ដើម្បីជួយសម្រួលដល់កិច្ចការរបស់ខ្លួន គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត អាចស្នើសុំបង្កើតអនុគណៈកម្មាធិការឬក្រុមការងារតាមការចាំបាច់ ឬតាមតម្រូវការនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

សមាសភាពអនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ អាចជ្រើសចេញពីសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មន្ត្រីអង្គភាពពាក់ព័ន្ធនៃសាលាខេត្ត សាលាក្រុង សាលាស្រុក និងមន្ទីរ អង្គភាពពាក់ព័ន្ធនានាតាមការចាំបាច់។

ក្រុមប្រឹក្សាខេត្ត ត្រូវសម្រេចអំពីការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ។ សេចក្តីសម្រេចនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាខេត្ត ផ្អែកតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន។

ជំពូកទី៣
គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង
ផ្នែកទី១
សមាសភាព និង តួនាទី ភារកិច្ច

មាត្រា ១២.-

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង មានសមាសភាពដូចខាងក្រោម :

- អភិបាលក្រុង ជាប្រធាន

- អភិបាលរងក្រុង០១រូប ជាអនុប្រធាន
- នាយករដ្ឋបាលសាលាក្រុង ជាសមាជិកអចិន្ត្រៃយ៍
- សមាជិកក្រុមប្រឹក្សាក្រុងយ៉ាងតិច០២រូប ជាសមាជិក
- ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលដែលប្រចាំនៅក្រុង ជាសមាជិក
- ប្រធានការិយាល័យទាំងអស់របស់សាលាក្រុង ជាសមាជិក
- ចៅសង្កាត់ទាំងអស់នៅក្នុងក្រុង ជាសមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាក្រុង០១រូប ជាសមាជិក

សមាសភាពអនុប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង ត្រូវស្នើដោយអភិបាលក្រុង។

ក្រុមប្រឹក្សាក្រុង ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង។ សេចក្តីសម្រេចនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាក្រុង។

មាត្រា ១៣.-

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង មានតួនាទី ភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុង លើកិច្ចការសំខាន់ៗដូចខាងក្រោម :

ក. ផែនការអភិវឌ្ឍ និងថវិកា

- ការដាក់បញ្ចូលផែនការអភិវឌ្ឍ និងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរ ការិយាល័យ អង្គភាពនានារបស់រាជរដ្ឋាភិបាលដែលបានផ្តល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាក្រុង
- សេចក្តីព្រាងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងការធ្វើបច្ចុប្បន្នភាព
- សេចក្តីព្រាងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាក្រុង
- សេចក្តីព្រាងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងការធ្វើបច្ចុប្បន្នភាព
- ការងារហិរញ្ញវត្ថុនិងថវិការបស់ក្រុមប្រឹក្សាក្រុង
- សេចក្តីព្រាងគម្រោងវិភាជន៍មូលនិធិវិនិយោគក្រុង ដើម្បីគាំទ្រដល់កម្មវិធីនានារបស់ក្រុង

- កៀរគរការគាំទ្រពីអ្នកពាក់ព័ន្ធនានាដល់គម្រោងវិនិយោគក្រុង
